# ខ្លឹមសារជំនឿលើព្រះយេស៊ូវគ្រីស្ទ ក្នុង៦មេរៀន

## មេរៀនទី៦ក សេចក្តីស្រលាញ់របស់ព្រះ

## បាននាំព្រះរាជបុត្រាឲ្យយាងមក

**លំនាំដើម**

**«ដ្បិតព្រះស្រឡាញ់មនុស្សលោកជាខ្លាំង បានជាទ្រង់ប្រទានព្រះរាជបុត្រាតែមួយរបស់ព្រះអង្គ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ។»** យ៉ូហាន ៣:១៦

**«ដ្បិតព្រះស្រឡាញ់មនុស្សលោកជាខ្លាំង»**

- ព្រះណាជាព្រះដែលស្រលាញ់មនុស្សលោក? ព្រះអាទិករ
- សេចក្តីស្រលាញ់របស់ព្រះអស្ចារ្យណាស់ ទ្រង់អាណិតមនុស្ស
- ព្រះអាទិករ ល្អបរិសុទ្ធនិងយុត្តិធម៌ដែរ ដូច្នេះបាបត្រូវតែសង
- មនុស្សសង្គ្រោះខ្លួនមិនបានទេ តែព្រះមានព្រះហឫទ័យសង្គ្រោះមនុស្ស
- ពាក្យទំនាយអំពីព្រះអង្គសង្គ្រោះដែលត្រូវយាងមកនោះ មានចាប់តាំងពីសម័យដើមមក។ សម្រាប់ប្រហែល៤000ឆ្នាំ អ្នកជឿលើព្រះអាទិករ គឺព្រះយេហូវ៉ា រងចាំការសម្រេចពីពាក្យទំនាយនោះ។

**«បានជាទ្រង់ប្រទានព្រះរាជបុត្រាតែមួយរបស់ព្រះអង្គ»**

- ព្រះអាទិករ ជាព្រះតែមួយគត់ តែមានបុគ្គលបីអង្គ
- ទាំងបីអង្គនោះមានភាពជាព្រះស្មើគ្នា អំណាចព្រះចេស្ដាដូចគ្នាទាំងអស់ តែមានការងារផ្សេងគ្នា ទួរនាទីខុសគ្នា
- បីអង្គនោះ គឺព្រះវរបិតា ព្រះរាជ្យបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ នេះជាអាថ៌កំបាំងមួយដែលយើងមិនអាចនឹងយោគយល់បាន

## «បានជាទ្រង់ប្រទានព្រះរាជបុត្រាតែមួយរបស់ព្រះអង្គ»

- ព្រះវរបិតាបានប្រទានព្រះរាជបុត្រា ឲ្យយាងមកពីឋានសួគ៌ លាក់សិរីល្អរបស់ទ្រង់ និងយកនិសាយជាមនុស្ស។
- ព្រះយេស៊ូវជាព្រះរាជបុត្រាដែលព្រះវរបិតាបានប្រទានឲ្យមក។
- ហេតុអ្វីបានជាព្រះវរបិតាចាត់ព្រះរាជបុត្រាឲ្យយាងមកយក  និស្ស័យជាមនុស្ស? ហេតុអ្វីសំខាន់អញ្ចើង?
- មនុស្សទុចរិតរួចហើយ ត្រូវតែមានព្រះអង្គដ៏ប្រោសលោះដែលសុចរិតពិតប្រាកត់វិញ។

**«ដូចដែលបាប បានចូលមកក្នុងពិភពលោកតាមរយៈមនុស្សម្នាក់ (លោកអ័ដាំ) ហើយសេចក្ដីស្លាប់ចូលមកតាមរយៈបាបជាយ៉ាងណា នោះសេចក្ដីស្លាប់ក៏រាលដាលដល់មនុស្សគ្រប់គ្នាយ៉ាងនោះដែរ ដ្បិតគ្រប់គ្នាបានធ្វើបាប។»** រ៉ូម ៥:១២

មនុស្សទាំងអស់ជាអ្នកទុចរិត។

**«ដូច្នេះ ដូចដែលអំពើរំលងរបស់មនុស្សម្នាក់ *(គឺលោកអ័ដាំ)* នាំឲ្យមនុស្សទាំងអស់ត្រូវទោសយ៉ាងណា នោះអំពើសុចរិតរបស់មនុស្សម្នាក់ *(គឺព្រះយេស៊ូវគ្រីស្ទ)* ក៏នាំឲ្យមនុស្សទាំងអស់បានសុចរិត និងបានជីវិតយ៉ាងនោះដែរ។»**

**«ដ្បិត ដូចដែលមនុស្សជាច្រើនបានត្រឡប់ជាមានបាប ដោយសារការមិនស្ដាប់បង្គាប់របស់មនុស្សម្នាក់ *(លោកអ័ដាំ)* យ៉ាងណា នោះមនុស្សជាច្រើន ក៏បានត្រឡប់ជាសុចរិត ដោយសារការស្ដាប់បង្គាប់របស់មនុស្សម្នាក់ *(ព្រះយេស៊ូវ)* យ៉ាងនោះដែរ។»** រ៉ូម ៥:១៨-១៩

យោងតាមព្រះគម្ពីរនេះ យើងឃើញថា មនុស្សដែលមានបាបសង្គ្រោះខ្លួនមិនបានទេ។ ត្រូវតែមានមនុស្សម្នាក់ដែលបរិសុទ្ធ គ្រប់លាក្ខណ ដែលសុចរិតពិតប្រាកដ់ ដែលមានប្រសិទ្ធិភាពប្រោសលោះមនុស្សលោកបាន។

អស់អ្នកណាដែលកើតមកជាធម្មតា មានឪពុក ហើយមានម្ដាយ កើតមកជាអ្នកមានបាបស្រាប់ហើយ។ ពីព្រោះលោកទាំងពីរនោះ ទួរបើជាលោកជាមនុស្សល្អ

ទាំងពីរអ្នកក៏ដោយ យើងដឹងថា ឪពុកម្តាយជាអ្នកមានបាបដូចជាយើងដែរ។ ដូច្នេះ ព្រះអង្គសង្គ្រោះមិនអាចកើតមកតាមពូចមនុស្សធម្មតាបានទេ។

ពាក្យទំនាយថា នៅពេលដែលព្រះសង្គ្រោះយាងមកយកនិស្ស័យជាមនុស្ស ទ្រង់ត្រូវប្រសូតមកក្នុងផ្ទៃរបស់នាងព្រហ្មចារីយម្នាក់។ ហេតុអ្វី? ព្រោះភាពជាអ្នកមានបាបចូលតាមរយៈពូជរបស់បុរស។ ក្នុងការអស្ចារ្យរបស់ព្រះ ព្រះរាជបុត្រាបានប្រសូតមកបែបនេះមែននៅប្រទេសអ៊ីស្រាអែល ទ្វីបអាស៊ីខាងលេច ២០២១ឆ្នាំមុន ដូចពាក្យទំនាយក្នុងព្រះគម្ពីរបានចែងទុកមក។

ថ្ងៃណូអែល
ព្រះនាម «យេស៊ូវ» មានន័យថា «ព្រះអង្គសង្គ្រោះ»

ប្រហែលលោកអ្នកធ្លាប់ឮអំពីអំណាចរបស់ព្រះយេស៊ូវ ដូចជា (លើកឧទាហរណ៍មក)

ប៉ុន្តែមានលក្ខណៈរបស់ព្រះយេស៊ូវមួយដែលសំខាន់មែនទែនមួយ គឺភាពបរិសុទ្ធរបស់ព្រះ។ ទ្រង់បានប្រសូតមកក្នុងភាពបរិសុទ្ធ ហើយទ្រង់បានរក្សារភាពបរិសុទ្ធនោះ រហូតដល់ទ្រង់បានសុគត។

ព្រះអង្គចេះអាណិតអាសូរ ដល់ភាពទន់ខ្សោយរបស់យើង

**«ព្រះអង្គត្រូវរងការល្បួងលគ្រប់បែបយ៉ាងដូចយើងដែរ តែមិនបានប្រព្រឹត្តអំពើបាបឡើយ។»** ហេប្រើរ ៤:១៥

ដូច្នេះ ព្រះយេស៊ូវធ្វើជាព្រះអង្គសង្គ្រោះ ជួយរំដោះមនុស្សយើងឲ្យរួចពីទោសបាបបាន! តាមរយព្រះយេស៊ូវ យើងផ្សះផ្សារជាមួយព្រះអាទិករកើត!

តើព្រះយេស៊ូវបានធ្វើអ្វីដើម្បីផ្សះផ្សាយើងនឹងព្រះអាទិករ? តើព្រះយេស៊ូវបានធ្វើអ្វីដើម្បីសង្គ្រោះយើងឲ្យរួចពីទោសបាបរបស់យើង?